ISSN 1560-7615 / ISBN 978-99950-52-06-5

# ទស្សនាវដ្ដី អភិវឌ្ឍន៍កម្ពុជា

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី ១៧ លេខ ២ | មិថុនា ឆ្នាំ២០១៣ | តម្លៃ ១.៥០០រ

## កំណែទម្រង់វិស័យជលផលនៅតំបន់បឹងទន្លេសាបៈ ហានិភ័យ និងឱកាសសម្រាប់ការអនុវត្តគំនិតច្នៃប្រឌិតថ្មី[១]

សេចក្ដីប្រកាសរបស់ សម្ដេចនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា កាលពីឆ្នាំ២០១២ ស្ដីពី ការលុបបំបាត់ប្រព័ន្ធឡូត៍នេសាទទឹកសាបឯកជនទាំងស្រុង ដែលជាកំណែទម្រង់វិស័យជលផលទឹកសាបលើកទី២ សម្រាប់តំបន់បឹងទន្លេសាប ពោលគឺតំបន់ផ្ដល់ផលនេសាទខ្ពស់ជាងគេបង្អស់នៅកម្ពុជា។ ទន្ទឹមគ្នានឹងការបង្កើត និងបង្កើនដែននេសាទសម្រាប់សហគមន៍ និងតំបន់អភិរក្សធនធានជលផល កំណែទម្រង់នេះ ក៏នៅមានជួបបញ្ហាប្រឈម និងការលំបាកក្នុងផ្នែកក្របខ័ណ្ឌស្ថាប័ន ព្រមទាំងនាំឲ្យកើតមានឡើងនូវជម្លោះថ្មីៗផងដែរ។



កិច្ចពិភាក្សាជាក្រុម ពីបញ្ហាជលផលនិងការគ្រប់គ្រងក្នុងពេលបច្ចុប្បន្ន នៅឃុំផាត់សណ្ដាយ ខេត្តកំពង់ធំ កាលពីថ្ងៃទី៥ ខែមករា ឆ្នាំ២០១២ ។

អត្ថបទសង្ខេបនេះ បង្ហាញលទ្ធផលទទួលបានពីដំណើរការស្រាវជ្រាវ និងកិច្ចសន្ទនានានា ដើម្បីស្វែងយល់ពីឱកាសល្អ និងហានិភ័យផុសចេញពីកំណែទម្រង់វិស័យជលផល និងដើម្បីគាំទ្រដល់ការអនុវត្តន៍គំនិតច្នៃប្រឌិតថ្មីនៅថ្នាក់មូលដ្ឋាន។ ដំណើរការនេះ បាននាំឲ្យមានសិក្ខាសាលាអំពីកំណែទម្រង់វិស័យជលផលក្នុងតំបន់បឹងទន្លេសាប រៀបចំដោយរដ្ឋបាលជលផល កាលពីថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១២ ដោយមានការចូលរួមពីតំណាងសហគមន៍នេសាទ អាជ្ញាធរមូលដ្ឋាន អង្គការសង្គមស៊ីវិល NGOs និងមន្ត្រីស្ថាប័នពាក់ព័ន្ធថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិជាច្រើន។[២]

### កំណែទម្រង់ ហានិភ័យ និង ឱកាសល្អៈ

**កំណែទម្រង់វិស័យជលផលទាំងពីរលើក មានគោលដៅស្រដៀងគ្នា តែក្នុងបរិបទខុសគ្នា។** កំណែទម្រង់វិស័យជលផលទឹកសាបនាពេលថ្មីៗនេះ ដែលផ្ដួចផ្ដើមឡើងដោយរដ្ឋាភិបាលថ្នាក់លើ គឺជាការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យជលផល ដ៏សំខាន់បំផុតមួយរបស់ប្រទេសកម្ពុជាក្នុងសម័យកាលនេះ ដើម្បីដោះស្រាយបញ្ហាការគ្រប់គ្រងធនធានធម្មជាតិ និងការអភិវឌ្ឍជនបទ។ កំណែទម្រង់លើកទី១ បានធ្វើឡើងក្នុងកំឡុងឆ្នាំ២០០០ និង ២០០១ ដោយលុបចោលផ្ទៃឡូត៍នេសាទក្នុងបឹងទន្លេសាបចំនួន ៥៦% ដើម្បីឲ្យទៅសហគមន៍ប្រើប្រាស់។ កំណែទម្រង់លើកទី២ ដែល

## មាតិកា

កំណែទម្រង់វិស័យជលផលនៅតំបន់បឹងទន្លេសាបៈ
ហានិភ័យ និង ឱកាសសម្រាប់ការអនុវត្តគំនិតច្នៃប្រឌិតថ្មី ...១
តួនាទីវិនិយោគផ្ទាល់ពីបរទេស ក្នុងការអភិវឌ្ឍឧស្សាហកម្ម
នៅកម្ពុជា ....................................................៥
ករណីសិក្សាៈ ខ្សែចង្វាក់តម្លៃទីផ្សារស្រូវនៅខេត្តតាកែវ ...........៨
តាមដានសេដ្ឋកិច្ច — ស្ថានភាពក្រៅប្រទេស ......................១៥
— ស្ថានភាពក្នុងប្រទេស........................១៧
ព័ត៌មានថ្មីៗពីវិទ្យាស្ថាន CDRI ....................................២៤

---

១ អត្ថបទនេះរៀបរៀងដោយលោក គឹម ស្ងួ ជាអ្នកស្រាវជ្រាវ និង លោក សូ សុវណ្ណារិទ្ធិ ជាអ្នកស្រាវជ្រាវជាន់ខ្ពស់ នៃវិទ្យាស្ថាន CDRI, លោក ម៉ម កុសល និង Blake Ratner នៃមជ្ឈមណ្ឌលត្រីពិភពលោក (Worldfish), និងលោក អៀ អ៊ីល នៃមជ្ឈមណ្ឌលសម្រាប់ការវិភាគបញ្ហាអភិវឌ្ឍន៍(ADIC)។

២ សិក្ខាសាលាពិគ្រោះយោបល់ និងការស្រាវជ្រាវ ដើម្បីគ្រប់គ្រងធនធានជលផល នៅបឹងទន្លេសាប CDRI បានរៀបចំឡើងដោយសហការជាមួយរដ្ឋបាលជលផល, Worldfish និង ADIC, និងជាផ្នែកមួយនៃកម្មវិធីឆ្លងតំបន់ដ៏ធំ ហៅថា "ការពង្រឹងអភិបាលកិច្ចធនធានជលផលៈ ការអនុវត្តបែបថ្មីផ្នែកស្ថាប័ន ដើម្បីកសាងសន្តិសុខស្បៀង និងកាត់បន្ថយទំនាស់នៅតំបន់អេកូឡូស៊ីនៃបឹង Victoria, បឹង Kariba និងបឹងទន្លេសាប/មេគង្គក្រោម" ដែលទទួលបានហិរញ្ញប្បទានពីក្រសួងសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ នៃប្រទេសអាល្លឺម៉ង់។ ដៃគូសហការផ្សេងទៀត រួមមានវិទ្យាស្ថានស្រាវជ្រាវ Adelphi នៅក្រុង Berlin និងអង្គការមិនមែនរដ្ឋាភិបាល (NGOs) ក្នុងស្រុកពីរ គឺ FACT និង HOM ដែលជួយគាំទ្រដល់ការការអនុវត្តបែបថ្មី នៅថ្នាក់មូលដ្ឋាន ក្នុងខេត្តកំពង់ធំ។ របាយការណ៍ពេញលេញគ្រោងនឹងចេញផ្សាយក្នុងពេលឆាប់ៗ។

ប្រព្រឹត្តិទៅនៅដើមឆ្នាំ២០១២ បាននាំមកនូវការលុបបំបាត់ ឡូត៍នេសាទទឹកសាបជាលក្ខណៈឧស្សាហកម្ម ចោលទាំងស្រុង។ កាលលុបឡូត៍នេសាទ ក្នុងជំហានចុងក្រោយនេះ បានទទួលការអបអរសាទរពីសំណាក់អង្គការអន្តរជាតិ អង្គការសង្គមស៊ីវិល សហគមន៍មូលដ្ឋាន និងអ្នកនេសាទក្នុងមូលដ្ឋាន ដែលមានជីវភាពរស់នៅពឹងផ្អែកទាំងស្រុងលើការធ្វើនេសាទ នៅក្នុងដែននេសាទក្នុងបឹងទន្លេសាប។ កំណែទម្រង់វិស័យជលផលនេះ បានផ្ដល់ឱកាសថ្មីៗ សម្រាប់ការគ្រប់គ្រងធនធានជលផលរួមគ្នា ដើម្បីលើកកម្ពស់ប្រាក់ចំណូលប្រជាជនមូលដ្ឋាន សន្តិសុខស្បៀង និងជីវភាពរស់នៅ។ ទោះជាយ៉ាងណា ក៏នៅមានការនេសាទ និងការប្រើប្រាស់ធនធានជលផលខុសច្បាប់ ដែលជាបញ្ហាចោទដ៏ធ្ងន់ធ្ងរផងដែរ។

កំណែទម្រង់វិស័យជលផលក្នុងឆ្នាំ២០០០ និង២០០១ បានអនុវត្តឡើងនៅពេលដែល ការធ្វើនេសាទជាលក្ខណៈឧស្សាហកម្ម កំពុងតែគ្របដណ្ដប់លើផ្ទៃបឹងទន្លេសាបទាំងមូល ហើយមានបញ្ហាប្រើប្រាស់ និងទំនាស់ រវាងអ្នកនេសាទគ្រួសារ និងម្ចាស់ឡូត៍នេសាទ កាន់តែចោទខ្លាំងឡើង។ ការផ្លាស់ប្ដូរពីការគ្រប់គ្រងបែបឧស្សាហកម្មទ្រង់ទ្រាយធំ ទៅជាការគ្រប់គ្រងធនធានជលផលតាមបែបសហគមន៍ ដោយយោងតាមគោលការណ៍វិមជ្ឈការ នាំឲ្យមានការប្រែប្រួលគួរឲ្យកត់សម្គាល់ ទៅលើសិទ្ធិរបស់អ្នកប្រើប្រាស់ធនធានជលផល។

កំណែទម្រង់វិស័យជលផល មានបំណងផ្ដល់ឱកាសកាន់តែច្រើន ដល់អ្នកនេសាទនៅមូលដ្ឋានក្នុងការនេសាទត្រី និងដើម្បីបង្កើនប្រាក់ចំណូលក្នុងគ្រួសារ ហើយក៏សំដៅការពារ និងអភិរក្សធនធានជលផល ឲ្យមានចីរភាពផងដែរ។ ក្នុងការអនុវត្តជាក់ស្ដែង គោលដៅទាំងនេះ ជួនកាលវាប្រជែងគ្នា ហើយបង្កជាភាពតានតឹង ដែលបន្តរហូតមកដល់ដំណាក់កាលបច្ចុប្បន្ន ។

កំណែទម្រង់វិស័យជលផលឆ្នាំ២០១២នេះ មានបំណងកសាងបន្តលើកំណែទម្រង់ពីលើកមុន និងជាចំណែកមួយនៃយុទ្ធនាការដ៏ធំធេង ដែលព្យាយាមដោះស្រាយទំនាស់កើតមានជារឿយៗនៅជុំវិញបឹងទន្លេសាប។ បញ្ហាត្រូវដោះស្រាយ រួមមានសំណើពង្រីកលទ្ធភាពរបស់សហគមន៍ ក្នុងការប្រើប្រាស់តំបន់នេសាទឲ្យមានភាពជាក់លាក់ ការថយចុះផលនេសាទចាប់បាន និងទំនាស់រវាងអ្នកនេសាទនឹងម្ចាស់ឡូត៍នេសាទ។ចំណុចសំខាន់មួយទៀត គឺរដ្ឋាភិបាលបានទទួលស្គាល់ថា ចំណូលដែលបានពីការជួលឡូត៍នេសាទបែបឧស្សាហកម្មចំពោះសេដ្ឋកិច្ចជាតិ វាមិនចាំបាច់ជាងការរកផលនេសាទ សម្រាប់ការចិញ្ចឹមជីវិតរបស់ប្រជានេសាទជាលក្ខណៈគ្រួសារនោះឡើយ។

**ការប្រញាប់ប្រញាល់ពេកក្នុងការចេញបទបញ្ញត្តិថ្មី។ បានបង្កនូវភាពភ័ន្តច្រឡំនិងការមិនពេញចិត្ត។**នៅក្នុងកំណែទម្រង់ទាំងពីរលើក គឺមានការប្រកាសលុបឡូត៍នេសាទជាមុន ទើបមានកំណត់នូវយន្តការ (អនុក្រឹត្យ ឬប្រកាស) សម្រាប់គ្រប់គ្រងកន្លែងអតីតឡូត៍នេសាទទាំងនោះ ជាក្រោយ។ កំណែទម្រង់លើកទី១ បានធ្វើឲ្យមានការបើកចំហទាំងស្រុង នូវការប្រើប្រាស់ធនធានជលផល (effectively open access) ក្នុងដំណាក់កាលដំបូង ហើយបន្ទាប់មកមានការអនុវត្តសាកល្បងជាច្រើនឆ្នាំ លើការបង្កើតសហគមន៍នេសាទ។ ប៉ុន្តែ ដោយក្របខ័ណ្ឌច្បាប់មានកម្រិតទន់ខ្សោយនៅឡើយនោះ ក៏ឲ្យមានភាពចន្លោះប្រហោង ដែលនាំឲ្យការធ្វើនេសាទបែបឧស្សាហកម្ម បន្តដំណើរការបាន ហើយសឹងតែរុញច្រានអ្នកនេសាទជាលក្ខណៈគ្រួសារចេញពីតំបន់នេសាទដែលសម្បូរត្រីទាំងស្រុង។ ក្នុងកំណែទម្រង់វិស័យជលផលក្នុងឆ្នាំ២០១២នេះ គេឃើញមានបរិធានច្បាប់ថ្មីៗ និងសេចក្ដីសម្រេចអំពីការកំណត់ឡើងវិញនូវ ដែននេសាទទឹកសាប បានកើតមានឡើងក្នុងរយៈពេលពីរបីខែ ក្រោយពីសេចក្ដីប្រកាសរបស់សម្ដេចនាយករដ្ឋមន្ត្រី។ លើសពីនេះ គេឃើញមានបង្កើតក្រុមការងារចម្រុះ ដើម្បីចុះបង្ក្រាបនិងដោះស្រាយបញ្ហានៅគ្រប់ទិសទី ដែលទាក់ទងនឹងការធ្វើនេសាទជាលក្ខណៈឧស្សាហកម្ម លក្ខណៈសិប្បកម្ម និងលក្ខណៈគ្រួសារ ដែលត្រូវបានចាត់ទុកថា ជាការនេសាទខុសច្បាប់ និងបង្កការបំផ្លិចបំផ្លាញដល់ធនធានមច្ឆាជាតិ។ កំណែទម្រង់វិស័យជលផលចុងក្រោយនេះ បានបែងចែកអតីតឡូត៍នេសាទ ក្នុងតំបន់បឹងទន្លេសាបប្រមាណ ៦៥% ទៅឲ្យសហគមន៍នេសាទ (Community Fisheries - CFi) និងប្រមាណ ៣៥% ទៀត សម្រាប់ធ្វើជាតំបន់អភិរក្សធនធានជលផល។

មនុស្សជាច្រើនបានសាទរ ចំពោះការលុបបំបាត់ឡូត៍នេសាទជាស្ថាពរក្នុងតំបន់បឹងទន្លេសាប ប៉ុន្តែនៅមានចំណុចមិនរលូនគ្នា ឬភាពប្រទាំងប្រទើសជាច្រើន រវាងអនុក្រឹត្យថ្មី មាត្រាមួយចំនួននៅក្នុងច្បាប់ជលផល និងបទបញ្ញត្តិផ្សេងៗ ដែលបានធ្វើឲ្យមានភាពភាន់ច្រឡំក្នុងចំណោមអ្នកគ្រប់គ្រងធនធានជលផល និងអ្នកនេសាទនៅថ្នាក់មូលដ្ឋាន។ ភាពមិនរលូនគ្នា និងភាពចន្លោះប្រហោងទាំងនេះ បានធ្វើឲ្យបទបញ្ញត្តិច្បាប់មានលក្ខណៈស្រពេចស្រពិល អាចបកស្រាយបានច្រើនយ៉ាង និងពិបាកយកទៅអនុវត្តនៅក្នុងស្ថានភាពជាក់ស្ដែង។ ប្រភពនៃភាពភាន់ច្រឡំនិងទំនាស់រួមមាន ការកំណត់ព្រំដែននេសាទ ការបញ្ជាក់ពីទំហំនៃដែននេសាទសហគមន៍ ការកំណត់និយមន័យនិងចំណាត់ថ្នាក់ ពីប្រភេទឧបករណ៍នេសាទ ដែលត្រូវបានអនុញ្ញាតប្រើប្រាស់ឲ្យបានច្បាស់ បទបញ្ញត្តិស្ដីពីទំហំក្រឡាមងដែលអនុញ្ញាតឲ្យប្រើប្រាស់ និងការបញ្ជាក់ពីតួនាទីនិងទំនួលខុសត្រូវ របស់អាជ្ញាធរគ្រប់គ្រង និងប្រតិបត្តិច្បាប់។

**សកម្មភាពនេសាទស្ទុះឡើងយ៉ាងលឿន ដោយអាចនឹងជួបហានិភ័យថ្មីៗទៀត៖** កំណែទម្រង់វិស័យជលផលឆ្នាំ២០១២ បានជួយឲ្យអ្នកនេសាទនៅថ្នាក់មូលដ្ឋាន មានលទ្ធភាពធ្វើនេសាទបានច្រើនជាងមុន។ ដោយនឹកឃើញពីកំណើនសកម្មភាពនេសាទដ៏ខ្លាំងក្លា ក្រោយពីពេលធ្វើកំណែទម្រង់លើកទី១ និងការផ្អាកការពង្រឹងអនុវត្តន៍ច្បាប់អស់មួយរយៈមកនោះ អ្នកនេសាទជាច្រើនបានប្រញាប់ប្រញាល់ធ្វើវិនិយោគលើ ឧបករណ៍នេសាទខ្នាតធំ (ដែលភាគច្រើនជាឧបករណ៍បំផ្លិចបំផ្លាញដល់ធនធានជលផល) ដើម្បីឆ្លៀតឱកាសយកប្រយោជន៍ពី ស្ថានភាពច្របូកច្របល់ក្រោយពីធ្វើកំណែទម្រង់ភ្លាមៗនាពេលនោះ។ ប៉ុន្តែមិនបានយូរប៉ុន្មាន មន្ត្រីជំនាញ បានហាមឃាត់ និងដកហូតឧបករណ៍នេសាទខុសច្បាប់ទាំងនោះអស់ជាច្រើន។

បច្ចុប្បន្ននេះ ថ្វីបើប្រជានេសាទ អាចធ្វើនេសាទបាននៅក្នុង

ដែននេសាទជាច្រើនក៏ដោយ ក៏នៅមានរបាយការណ៍ថាមានអ្នកនេសាទមូលដ្ឋានក្រីក្រជាច្រើននាក់ នៅតែមិនទាន់អាចដកយកធនធានជលផលទាំងនោះ ឲ្យបានទាន់គេ ដោយសារតែពួកគាត់ពុំមានថវិកាគ្រប់គ្រាន់ ទិញឧបករណ៍នេសាទយកមកប្រើប្រាស់។ កំណែទម្រង់នេះ ក៏អាចបង្កើតជាហានិភ័យដល់ផ្នែកអេកូឡូស៊ីថ្មីៗថែមទៀត ព្រោះមានប្រជាជនកាន់តែច្រើនឡើងៗ ទៅធ្វើនេសាទពិសេសនៅតាមតំបន់បឹងព្រៃកជុំវិញបឹងទន្លេសាប ដែលមានទឹកជន់លិចនៅរដូវវស្សា ទាំងនេះគឺជាការដាក់សម្ពាធកាន់តែខ្លាំងទៅលើទីជម្រកត្រីដែលងាយនឹងរងនូវការប៉ះពាល់។

**បញ្ហាប្រឈម និងឱកាសថ្មីៗសម្រាប់សហគមន៍នេសាទ៖** គណៈកម្មាធិការសហគមន៍នេសាទភាគច្រើន មិនទាន់បានត្រៀមខ្លួនជាស្រេច ក្នុងន័យលក្ខណៈបច្ចេកទេស និងក្របខ័ណ្ឌស្ថាប័ន ដើម្បីទទួលខុសត្រូវលើការគ្រប់គ្រងដែននេសាទរបស់ខ្លួន ដែលកាន់តែធំនោះឡើយ។ ថ្វីបើសហគមន៍នេសាទទាំងអស់នៅតំបន់បឹងទន្លេសាបបានចុះបញ្ជីរួចហើយក្ដី ប៉ុន្តែមានសហគមន៍ជាច្រើនអាចនៅខ្វះខាតលើការយល់ដឹងពីសិទ្ធិស្របច្បាប់ តួនាទី និងទំនួលខុសត្រូវរបស់ខ្លួន ហើយអាចមានសមាជិកគណៈកម្មាធិការមួយចំនួននៅខ្វះការតាំងចិត្ត និងអាចមានភាពទន់ខ្សោយ ក្នុងការលើកកម្ពស់ចំណាប់អារម្មណ៍របស់សហគមន៍ខ្លួន និងក្នុងការសហការជាមួយស្ថាប័នរដ្ឋាភិបាលដែលពាក់ព័ន្ធទាំងអស់។លើសពីនេះ វាក៏អាចធ្វើឲ្យថយចុះនូវការឧបត្ថម្ភលើកទឹកចិត្ត ក្នុងការខិតខំប្រឹងប្រែងធ្វើការងារគ្រប់គ្រង និងការពារតំបន់នេសាទសហគមន៍ នៅពេលដែលមានការពង្រីក និងបង្កើនបរិមាណនិងទំហំដែននេសាទសម្រាប់អ្នកនេសាទគ្រួសារ នៅក្នុងបឹងទន្លេសាប។ គណៈកម្មាធិការដឹកនាំសហគមន៍នេសាទក៏បារម្ភដែរថា ដែននេសាទសហគមន៍ដែលបង្កើត និងបង្កើនថ្មីៗ និងបែងចែកមកឲ្យសហគមន៍គ្រប់គ្រងនោះវាអាចមានទំហំធំហួសពីសមត្ថភាពគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពរបស់ គណៈកម្មាធិការសហគមន៍។

កំណែទម្រង់ច្បាប់ និងគោលនយោបាយ គឺជាការចាំបាច់សម្រាប់ដោះស្រាយបញ្ហាប្រឈម និងការលំបាកទាំងឡាយដែលទាក់ទងនឹង ការគ្រប់គ្រងធនធានជលផលដោយមានចីរភាព និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជានេសាទ ក្នុងតំបន់បឹងទន្លេសាបឲ្យបានធូរធាររីកចម្រើន ប៉ុន្តែកំណែទម្រង់ច្បាប់ និងគោលនយោបាយនេះហាក់នៅមិនទាន់គ្រប់គ្រាន់នៅឡើយ។ វាជាការសំខាន់ណាស់ ដែលត្រូវមានសកម្មភាពកសាងសមត្ថភាពតួអង្គពាក់ព័ន្ធនៅគ្រប់លំដាប់ថ្នាក់ ដោយរួមទាំងការពង្រឹងកិច្ចសហប្រតិបត្តិការ រវាងផ្នែកពាក់ព័ន្ធផ្សេងទៀត (ឧទាហរណ៍ ផ្នែកនេសាទ ផ្នែកវារីវប្បកម្ម និងផ្នែកអភិរក្សធនធានជលផល) និងរវាងដែនសមត្ថកិច្ចនានា (ឧទាហរណ៍ ពីកម្រិតភូមិ ទៅដល់កម្រិតបឹងទន្លេសាបទាំងមូល) ដើម្បីគ្រប់គ្រងនិងប្រើប្រាស់ធនធានជលផលប្រកបដោយសមធម៌ ។ ក្នុងន័យនេះ សំណួរសំខាន់ៗមួយចំនួន ដែលត្រូវដោះស្រាយ រួមមាន៖

- **ការពង្រឹងសមត្ថភាពអនុវត្តន៍ច្បាប់៖** តើការត្រួតពិនិត្យតាមដានលើការធ្វើនេសាទ និងការអនុវត្តច្បាប់ ត្រូវបានពង្រឹងឡើងយ៉ាងណា ដើម្បីទ្រទ្រង់ដល់ការអនុវត្តគោលនយោបាយថ្មី?
- **វិធានការណ៍អភិរក្សធនធានជលផល៖** តើយើងត្រូវកែប្រែអ្វីខ្លះដល់ទីជម្រកត្រី និងតំបន់ការពារធម្មជាតិ ដើម្បីទ្រទ្រង់ដល់ការស្តារប្រព័ន្ធអេកូឡូស៊ីឲ្យបានល្អឡើងវិញ? តើកិច្ចប្រឹងប្រែងរបស់សហគមន៍នេសាទ និងស្ថាប័នពាក់ព័ន្ធផ្សេងៗត្រូវសម្របសម្រួលគ្នាយ៉ាងណា ដើម្បីទ្រទ្រង់ដល់ការអភិរក្សធនធានជលផល?
- **ការពង្រឹងសហគមន៍នេសាទ៖** តើសិទ្ធិអំណាច និងសមត្ថភាពសហគមន៍នេសាទត្រូវពង្រឹងឡើងយ៉ាងណា? តើគួរតម្រង់ទិសសហគមន៍នេសាទទាំងនេះ ទៅជាបែបណា ដើម្បីលើកកម្ពស់ជីវភាពសមាជិកសហគមន៍ ហើយព្រមគ្នានេះ ដើម្បីធានាឲ្យបាននូវការប្រើប្រាស់ធនធានជលផលឲ្យមានចីរភាព?

## ផ្នែកដែលគួរអនុវត្តតាមគំនិតច្នៃប្រឌិតថ្មី

**ការធ្វើបច្ចុប្បន្នភាព និងការបញ្ជាក់បំភ្លឺលើ បទបញ្ញត្តិនេសាទនានា៖** ប្រកាសលេខ១២៩ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីការកំណត់ឧបករណ៍នេសាទគ្រួសារ ត្រូវបានអនុម័តចេញភ្លាមៗ ដើម្បីជំរុញការអនុវត្តតាមកំណែទម្រង់គោលនយោបាយថ្មី។ ប៉ុន្តែដោយប្រកាសនេះត្រូវបានដាក់អនុវត្តន៍ ដោយមានការពិគ្រោះយោបល់តិចតួចពេក និងត្រូវបានបង្កើតឡើងតាមបែបផែនមួយ ដែលពុំបានគិតគូរពីបរិបទខុសៗគ្នាទៅតាមតំបន់ ដូច្នេះវិធានការនេះ ឬប្រកាសលេខ១២៩នេះ មិនបានដោះស្រាយ ឬឆ្លើយតបនឹងទំនាស់ ឬបញ្ហាទាក់ទងនឹងការប្រើឧបករណ៍នេសាទដែលត្រូវបានអនុញ្ញាត ដើម្បីផ្តល់ជាមូលដ្ឋានមួយសម្រាប់ការពង្រឹងការអនុវត្តច្បាប់ឲ្យបានរលូន។ ដំណើរការធ្វើវិសោធនកម្មក្របខ័ណ្ឌច្បាប់ គួរតែប្រព្រឹត្តិទៅដោយមានការចូលរួមក្នុងការពិគ្រោះយោបល់ អំពីអ្នកពាក់ព័ន្ធនានា ជាពិសេសអ្នកនេសាទនៅតាមមូលដ្ឋាន និងអ្នកទទួលផលពីធនធានជលផលឯទៀតដែលរស់នៅជុំវិញបឹងទន្លេសាប ដើម្បីចាប់យកគំនិត ទស្សនៈ និងបំណងប្រាថ្នារបស់ប្រជាជនមូលដ្ឋាន សំដៅធ្វើឲ្យបទបញ្ញត្តិជលផល មានខ្លឹមសារសមស្របនឹងស្ថានភាពបច្ចុប្បន្ននៃការធ្វើនេសាទ និងតម្រូវការការពារធនធានជលផល ហើយអាចយកទៅអនុវត្តបានដោយមានប្រសិទ្ធភាពខ្ពស់។

លើសពីនេះ ការបញ្ជាក់ឲ្យបានច្បាស់លាស់ ពីដែនកំណត់នៃការធ្វើនេសាទជាលក្ខណៈគ្រួសារ អាចចាត់ទុកជាលក្ខខណ្ឌដ៏ចាំបាច់ ដើម្បីឈានទៅអនុវត្តការគ្រប់គ្រងធនធានជលផលតាមជម្រើសណាមួយឲ្យបានជោគជ័យ ពីព្រោះវាអាចជួយពង្រឹងវិធានការអនុវត្តច្បាប់ និងអភិរក្សធនធានជលផល។ ទោះជាយ៉ាងណា ហានិភ័យចម្បងៗដែលទាក់ទងនឹងការកែប្រែបទបញ្ញត្តិគឺការអាចមានលេចចេញជាទំនាស់ថ្មីៗ និងអាចនាំឲ្យមានវិនិយោគិនលើឡូត៍នេសាទវិលត្រឡប់មកវិញ ហើយធ្វើការកេងប្រវ័ញ្ចយកផលប្រយោជន៍ ពីធនធានជលផលរបស់សហគមន៍នេសាទសាជាថ្មីម្តងទៀត។

**ការពង្រឹងទំនាក់ទំនងរវាងសហគមន៍នេសាទ និងអាជ្ញាធរមូលដ្ឋាន៖** ការកសាងភាពជាដៃគូរវាងសហគមន៍នេសាទ និងអាជ្ញាធរមូលដ្ឋាន អាចបង្កើតនូវលក្ខខណ្ឌផ្សេងៗ សម្រាប់ឲ្យសហគមន៍នេសាទអាចធ្វើការជាមួយគ្នា ដើម្បីសម្រេចគោលដៅ

រួម នៃការអភិរក្សធនធានជលផល ការពង្រឹងការអនុវត្តច្បាប់ និងការកសាងជីវភាពរស់នៅរបស់ប្រជាជន ឲ្យកាន់តែមានប្រសិទ្ធភាព និងកាន់តែប្រសើរឡើង។ ពិសេសទៅទៀត ការដាក់បញ្ចូលគ្នានូវផែនការរបស់សហគមន៍នេសាទ ទៅក្នុងផែនការវិនិយោគឃុំ-សង្កាត់ វាអាចជួយផ្ដល់ជាការគាំទ្រផ្នែករដ្ឋបាលនិងហិរញ្ញវត្ថុ សម្រាប់ការអនុវត្តផែនការគ្រប់គ្រងសហគមន៍នេសាទនៅក្នុងឃុំ-សង្កាត់នោះ ហើយដែលនឹងអាចជួយពង្រឹងដល់គោលដៅ នៃគោលនយោបាយវិមជ្ឈការនាពេលបច្ចុប្បន្ន។ ការធ្វើសមាហរណកម្មនេះ គឺជាមធ្យោបាយមួយ សម្រាប់ជួយដោះស្រាយបញ្ហាប្រជែងដណ្ដើមធនធានគ្នា រវាងវិស័យជលផល និងវិស័យផ្សេងៗទៀតផងដែរ ជាពិសេសទំនាស់ដែលតែងតែកើតមានឡើងលើការរានព្រៃលិចទឹក ការពង្រីកដីធ្វើស្រែប្រាំង ការបែងចែកទឹកនៅរដូវប្រាំង និងការការពារ ឬការស្ដារឡើងវិញនូវព្រៃលិចទឹក។ ទោះជាយ៉ាងណាក៏ដោយ ក៏មានហានិភ័យនានាដែលពាក់ព័ន្ធនឹងសមាហរណកម្មនេះ រួមមាន គណៈកម្មាធិការសហគមន៍នេសាទ អាចបាត់បង់ឯករាជ្យភាពក្នុងដំណើរការនេះ នៅពេលមានតំណាងក្រុមប្រឹក្សាឃុំ-សង្កាត់មកចូលរួម សហគមន៍នេសាទអាចខ្វះការលើកទឹកចិត្តក្នុងការកសាង សំណើដ៏រឹងប៉ឹងមួយឲ្យធ្វើវិនិយោគទៅលើ ការគ្រប់គ្រងធនធាននៅក្នុងឃុំ-សង្កាត់ ពីព្រោះវាផ្ទុយគ្នានឹងគម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ ដែលក្រុមប្រឹក្សាឃុំ-សង្កាត់ ធ្លាប់តែផ្ដល់អាទិភាពឲ្យនោះ។

**ការពង្រឹងការអនុវត្តច្បាប់ និងការយាមល្បាតរួមគ្នា៖** ការពង្រឹងការអនុវត្តច្បាប់ជលផល ក្នុងដែននេសាទ និងដែនអភិរក្ស ដោយមានការចូលរួមពីសហគមន៍មូលដ្ឋាន អាជ្ញាធរមូលដ្ឋាន រដ្ឋបាលជលផល និងស្ថាប័នពាក់ព័ន្ធផ្សេងទៀត អាចជួយលើកកម្ពស់ប្រសិទ្ធភាព ប្រសិទ្ធផល តម្លាភាព និងគណនេយ្យភាព នៃកិច្ចប្រឹងប្រែងក្នុងការពង្រឹងការអនុវត្តច្បាប់នេះ។ ដោយសារស្ថាប័ននីមួយៗមានចំណុចខ្លាំង និងខ្សោយរៀងៗខ្លួន ដូច្នេះការធ្វើការរួមគ្នាបែបនេះជួយបំពេញឲ្យគ្នាទៅវិញទៅមក ហើយអាចផ្ដល់លទ្ធផលល្អ ក្នុងកិច្ចប្រឹងប្រែងលុបបំបាត់ការនេសាទខុសច្បាប់។

នៅក្នុងតំបន់ដែលមានការធ្វើស្រែប្រាំង និងតំបន់ការពារធនធានជលផលដោយសហគមន៍ ការអនុវត្តច្បាប់ដោយមានការចូលរួមពីអ្នកពាក់ព័ន្ធនានានៅថ្នាក់មូលដ្ឋាន មានសារៈសំខាន់ជាខ្លាំង ។ នៅតាមតំបន់ព្រៃលិចទឹកមួយចំនួន ភាពតានតឹងរវាងកសិករស្រែប្រាំង ជាមួយនឹងសហគមន៍នេសាទ បានកើនឡើងខ្លាំង ក្នុងការគ្រប់គ្រងនិងប្រើប្រាស់ទឹក ក្នុងការប្រើប្រាស់ដី និងការការពារតំបន់ព្រៃលិចទឹក។ ក្នុងកាលៈទេសៈបែបនេះ ឆន្ទៈនយោបាយរបស់អាជ្ញាធរមូលដ្ឋាន មានតួនាទីដ៏សំខាន់ក្នុងការជួយគាំទ្រដល់កិច្ចសម្របសម្រួល និងសហការគ្នាក្នុងការដោះស្រាយ និងពង្រឹងការអនុវត្តច្បាប់។

**ការពិចារណា ទៅលើរបៀបគ្រប់គ្រងធនធានជលផលបែបថ្មី នៃសហគមន៍ផលិតកម្ម៖** នាពេលថ្មីៗនេះ គំនិតច្នៃប្រឌិតបែបថ្មីនៃសហគមន៍ផលិតកម្ម បាននិងកំពុងក្លាយជាគំរូមួយដែលអាចបង្កើនការលើកទឹកចិត្ត និងការឧបត្ថម្ភផ្នែកហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងដោយសមាជិកសហគមន៍នេសាទ។ វិធីសាស្ត្របែបថ្មីនេះ មិនទាន់អាចសមស្របសម្រាប់គ្រប់តំបន់ក៏ពិតមែន ក៏ប៉ុន្តែ វាគួរឲ្យយកមកពិចារណាផងដែរ នៅពេលដែលមានធនធានជលផលជាសក្ដានុពលសម្រាប់ឲ្យ សហគមន៍នេសាទធ្វើអាជីវកម្មក្នុងលក្ខណៈឧស្សាហកម្ម នៅក្នុងដែននេសាទសហគមន៍ដោយមានចីរភាព។ នៅក្នុងសិក្ខាសាលាពិគ្រោះយោបល់កាលពីខែធ្នូ ឆ្នាំ២០១២ អ្នកតំណាងសហគមន៍នេសាទបានបង្ហាញពីចំណាប់អារម្មណ៍ ចំពោះវិធីសាស្ត្របែបថ្មីនេះ ហើយបញ្ជាក់ថាវាជាមធ្យោបាយមួយ ដើម្បីបង្កើតចំណូលសម្រាប់ដោះស្រាយលើចំណាយប្រតិបត្តិការរបស់ សហគមន៍នេសាទ ពិសេសកិច្ចប្រឹងប្រែងបន្ថែម ដើម្បីការពារ និងគ្រប់គ្រងដែននេសាទសហគមន៍ ដែលមានទំហំធំ។ ការបង្កើតចំណូលសហគមន៍សម្រាប់ការគ្រប់គ្រងធនធានជលផលតាមបែបសហគមន៍ផលិតកម្មអាចផ្ដល់ជាកម្លាំងចិត្តដល់សមាជិកសហគមន៍ ឲ្យចូលរួមកាន់តែច្រើននិងមានប្រសិទ្ធភាពឡើង ក្នុងការងារគ្រប់គ្រងរួមគ្នា ដោយឈរលើគោលការណ៍ជាមូលដ្ឋាននៃ ការលើកស្ទួយជីវភាពរស់នៅរបស់សមាជិកសហគមន៍នេសាទ។

ទោះជាយ៉ាងណាក៏ដោយ ក៏របៀបគ្រប់គ្រងធនធានជលផលបែបថ្មី នៃសហគមន៍ផលិតកម្មនេះ នឹងអាចមានជួបឧបសគ្គនិងការលំបាកជាច្រើន ដែលរារាំងដល់ការអនុវត្តក្នុងលក្ខណៈជាក់ស្ដែង។ មន្ត្រីរដ្ឋាភិបាលនៅមិនទាន់ទុកចិត្តទៅលើគំនិតបែបថ្មីនៅតាមមូលដ្ឋាន ក្នុងការបង្កើតចំណូលសហគមន៍នៅឡើយទេ ហើយតែងតែចោទសួរថា តើគំនិតបែបថ្មីទាំងនេះ វាស្របទៅតាមគោលការណ៍ច្បាប់ក្នុងកម្រិតណាដែរ ហើយត្រូវការពេលយូរប៉ុណ្ណា ដើម្បីដាក់អនុវត្តវិធីសាស្ត្រគ្រប់គ្រងបែបនេះក្នុងលក្ខណៈជាក់ស្ដែង។ ហើយក៏នៅមានបញ្ហាមិនទាន់ដោះស្រាយរួចមួយចំនួនទៀត រួមមាន៖ ១) តើផ្ទៃដែននេសាទសហគមន៍មានទំហំធំប៉ុណ្ណា ដែលស័ក្ដិសមនឹងសមត្ថភាពគ្រប់គ្រង របស់គណៈកម្មាធិការសហគមន៍នេសាទ ២) កម្រិតនៃសិទ្ធិអំណាចរបស់គណៈកម្មាធិការសហគមន៍នេសាទ ក្នុងនេះមានទាំងសិទ្ធិហាមឃាត់អ្នកនេសាទ និងអ្នកប្រើប្រាស់ធនធានជលផល ដែលចូលមកពីខាងក្រៅផង ៣) តើប្រាក់ចំណូលដែលរកបានពីការធ្វើសហគមន៍ផលិតកម្ម ត្រូវគ្រប់គ្រងយ៉ាងដូចម្ដេច ហើយផលប្រយោជន៍នេះត្រូវបែងចែកយ៉ាងណា ដល់សមាជិកសហគមន៍ទាំងមូល ៤) តួនាទី និងទំនួលខុសត្រូវរបស់ស្ថាប័នពាក់ព័ន្ធផ្សេងៗ ក្នុងការចូលរួមគ្រប់គ្រងរួមគ្នា ការពិនិត្យតាមដានការបង្កើតវិធានការផ្សេងៗ និង ៥) តើអ្នកណាត្រូវផ្ដល់ជំនួយទ្រទ្រង់ ដល់ការកសាងសមត្ថភាពដ៏ចាំបាច់នានា។

## ការតាំងចិត្តធ្វើការពិសោធន៍សាកល្បង និងរៀនសូត្រតទៅអនាគត

អ្នកចូលរួមក្នុងវេទិកាសិក្ខាសាលាពិគ្រោះយោបល់ ពីកំណែទម្រង់វិស័យជលផល ក្នុងតំបន់បឹងទន្លេសាប កាលពីខែធ្នូ ឆ្នាំ២០១២ បានឆ្លុះបញ្ចាំងពីសារៈសំខាន់ នៃការចូលរួមពីថ្នាក់មូលដ្ឋានក្នុងការបង្កើតច្បាប់និងគោលនយោបាយផ្សេងៗ ដែលពាក់ព័ន្ធដល់សហគមន៍នេសាទ។ អ្នកចូលរួមយល់ថា ក្របខ័ណ្ឌច្បាប់ផ្សេងៗ ដែលបង្កើតឡើងដោយមិនមានការពិគ្រោះយោបល់ជាមួយសហគមន៍នេសាទ វាអាចមិនសមស្រប និងមិនឆ្លើយតប


តទៅទំព័រ ១៤

រូបភាព ៤៖ ការសម្របសម្រួលផ្ដល់ព័ត៌មានក្នុងខ្សែចង្វាក់តម្លៃ




ផលិតកម្មស្រូវសរុបនៅខេត្តតាកែវ ជាអតិរេកស្រូវ ដែលបង្ហាញពីសក្ដានុពលដ៏ធំសម្រាប់ការនាំចេញ។ ប៉ុន្តែកង្វះវិនិយោគជាមូលធនទៅលើរោងកិនស្រូវ និងបច្ចេកវិទ្យាកិនស្រូវទំនើបៗ បានកាត់បន្ថយសមត្ថភាពកែច្នៃអតិរេកស្រូវនេះ ធ្វើឲ្យស្រូវមួយភាគធំត្រូវបាននាំចេញ ជាពិសេសទៅកាន់ប្រទេសវៀតណាម។ ពាណិជ្ជករវៀតណាម ហាក់ដូចអាចគ្រប់ដណ្ដប់បានលើពាណិជ្ជកម្មស្រូវនេះ ដោយពួកគេជាអ្នកកំណត់ថ្លៃ និងស្ដង់ដាគុណភាព ហើយក៏អាចឆ្លៀតឱកាសបន្ទាបគុណភាព និងបញ្ចុះថ្លៃស្រូវ។ ដូច្នេះ កម្ពុជាចាំបាច់ត្រូវចាត់វិធានការដើម្បីធ្វើចំណាត់ថ្នាក់គុណភាពស្រូវ ដែលអាចធ្វើឲ្យពាណិជ្ជកម្មមានលក្ខណៈយុត្តិធម៌សម្រាប់ភាគីទាំងសងខាង។

## ការពាក់ព័ន្ធដល់គោលនយោបាយ

កសិករត្រូវប្រឈមមុខនឹងចំណាយផលិតកម្មខ្ពស់ និងថ្លៃទិញលក់ទាបៗនៅកសិដ្ឋាន។ ចំណុចនេះបង្ហាញពីតម្រូវការកាត់បន្ថយចំណាយផលិតកម្ម ជាពិសេសចំណាយហួសពីសមត្ថភាពគ្រប់គ្រងរបស់ផលិតករ និងកែលំអថ្លៃទិញលក់នៅកសិដ្ឋានសម្រាប់ទាំងស្រូវប្រាំង និងស្រូវវស្សា។

ការវិភាគខ្សែចង្វាក់តម្លៃបង្ហាញថា ស្រូវនៅខេត្តតាកែវមិនទាន់បំពេញបានតាមស្ដង់ដារសម្រាប់នាំចេញទេ។ សកម្មភាពផ្សេងៗដែលគួរពិចារណាសម្រាប់ផ្នែកផលិតកម្មរួមមានការណែនាំឲ្យប្រើពូជស្រូវមានគុណភាពល្អ ការចែកចាយនិងផ្លាស់ប្ដូរគ្រាប់ពូជជាថ្មីឲ្យបានទៀងទាត់ និងការផ្ដល់សេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្មស្ដីពី វិធីល្អៗក្នុងការដាំស្រូវ ដូចជា ការគ្រប់គ្រងបញ្ហាសត្វចង្រៃ និងការកែលំអគុណភាពដី និងការប្រើជី។ សកម្មភាពទាំងនេះអាចឲ្យកសិករកាត់បន្ថយចំណាយផ្សេងៗ ជាពិសេសទៅលើជី និងថ្នាំសម្លាប់សត្វចង្រៃ ព្រមទាំងទទួលបានទិន្នផលស្រូវកាន់តែខ្ពស់ និងមានគុណភាពស្របតាមស្ដង់ដារនាំចេញ ដែលនឹងផ្ដល់នូវថ្លៃទីផ្សារកាន់តែប្រសើរ។

ទីផ្សារស្រូវមានរចនាសម្ព័ន្ធល្អនៅខេត្តតាកែវ ជួយឲ្យកសិករអាចលក់ស្រូវបានតាមតម្លៃទីផ្សារប្រកួតប្រជែង។ អតិរេកស្រូវគេអាចកិនវា និងលក់ដូរវាប្រកបដោយប្រសិទ្ធភាពនៅក្នុងទីផ្សារមូលដ្ឋាន ប៉ុន្តែសមត្ថភាពកិនស្រូវកម្រិតទាប និងកង្វះវិនិយោគជាមូលធន ធ្វើឲ្យផ្នែកកិនស្រូវនេះមិនអាចកែច្នៃអតិរេកស្រូវទាំងអស់បានទេ។ ដូច្នេះការនាំចេញស្រូវនៅតែសំខាន់បំផុត ប៉ុន្តែនាបច្ចុប្បន្ន អតិរេកស្រូវត្រូវបានដោះដូរតែជាមួយប្រទេសវៀតណាមប៉ុណ្ណោះ។ កម្ពុជាបានចុះហត្ថលេខាលើអនុស្សារណៈយោគយល់គ្នាជាមួយប្រទេសវៀតណាម ដើម្បីនាំចេញ និងនាំចូលស្រូវ ប៉ុន្តែការផ្លាស់ប្ដូរក្នុងគោលនយោបាយពាណិជ្ជកម្មស្រូវអង្ករបស់វៀតណាម តាមរយៈការយកពន្ធគយកាន់តែច្រើន ការកំណត់កូតា ឬការបិទព្រំដែនដើម្បីការពារទីផ្សារក្នុងស្រុក អាចធ្វើឲ្យវិស័យស្រូវនៅខេត្តតាកែវ ជួបនឹងវិបត្តិ។ វិធានការសុវត្ថិភាពសេដ្ឋកិច្ចដ៏សំខាន់មួយ សម្រាប់ទប់ទល់នឹងហានិភ័យនៃការរអាក់រអួលបែបនេះ គឺការបើកដំណើរការនូវខ្សែចង្វាក់នាំចេញស្រូវរបស់កម្ពុជាមួយឡើង៕

ឯកសារយោងមាននៅក្នុងអត្ថបទជាអង់គ្លេស

*តពីទំព័រ ៤* **កំណែទម្រង់វិស័យជលផល...**

ទៅតាមតម្រូវការរបស់ប្រជាជននៅមូលដ្ឋាន ហើយវាអាចបង្កើតឲ្យមានភាពតានតឹងរវាងសហគមន៍ នឹងអង្គភាពប្រតិបត្តិច្បាប់។ ប៉ុន្តែភាពយឺតយ៉ាវពេកក្នុងការសម្រេចចិត្ត ឬដាក់អនុវត្តច្បាប់ថ្មីៗ ក៏អាចបង្កជាបញ្ហាផងដែរ។ ដូច្នេះ ការស្វែងរកផ្លូវកណ្ដាល ដើម្បីសម្រេចបានទាំងការចូលរួមប្រកបដោយប្រសិទ្ធភាព និងការអនុវត្តទាន់ពេលវេលានោះ មិនមែនជាការងាយស្រួលឡើយ។

ឯកឧត្តមអគ្គនាយកប្រធានរដ្ឋបាលជលផល បានបញ្ជាក់នៅក្នុងវេទិកាអង្គសិក្ខាសាលានោះថា ការអនុវត្តកំណែទម្រង់វិស័យជលផលបាន និងកំពុងជួបប្រទះបញ្ហាប្រឈមជាបន្តបន្ទាប់ ដូច្នេះ ត្រូវមានការប្រាស្រ័យទាក់ទងគ្នាជាចំហ រវាងតួអង្គពាក់ព័ន្ធទាំងអស់ និងត្រូវមានឆន្ទៈក្នុងការពិសោធន៍សាកល្បង និងរៀនសូត្ររួមគ្នា។ ការប្ដេជ្ញាចិត្តធ្វើការពិសោធន៍សាកល្បង និងរៀនសូត្ររួមគ្នា ត្រូវមានដំណើរការអនុវត្តន៍នូវគំនិតឆ្នៃប្រឌិតថ្មីៗថែមទៀត ដើម្បីបំផុសគំនិតបែបថ្មីនៅថ្នាក់មូលដ្ឋាន ចងក្រងមេរៀនបទពិសោធន៍ដែលរៀនសូត្របាន ហើយយកទៅប្រើប្រាស់ ក្នុងកិច្ចខំប្រឹងប្រែងធ្វើកំណែទម្រង់ស្ថាប័ន និងគោលនយោបាយដែលទាក់ទងទៅនឹងវិស័យជលផលនាពេលអនាគត។ ស្ថាប័នរដ្ឋាភិបាលដែលពាក់ព័ន្ធ និងភ្នាក់ងារជលផលនៅតាមមូលដ្ឋានក៏ត្រូវមានសមត្ថភាពនិងចំណេះដឹងថ្មីៗបន្ថែមទៀត ដើម្បីជួយទ្រទ្រង់ដល់ការអនុវត្តវិធីសាស្ត្រនេះ។

បឹងទន្លេសាបជាប្រព័ន្ធអេកូឡូស៊ីមួយដ៏ធំទូលាយ មានលក្ខណៈស្មុគស្មាញ និងងាយខ្ទេចខ្ទាំ។ ប្រព័ន្ធនេះបានជួយទ្រទ្រង់ដល់

*តទៅទំព័រ ១៨*

(M1) កើន ២,៣% ហើយរូបិយវត្ថុផ្សេងៗកើន ៤៤,៦%។ ទ្រព្យសកម្មក្នុងស្រុកសុទ្ធកើន ២៤,៣% ធៀបនឹងត្រីមាសមុន (៨១,២% ធៀបមួយឆ្នាំមុន) ក្នុងនោះឥណទេយ្យលើរដ្ឋាភិបាលសុទ្ធកើន ១,៩% (១៧,១% ធៀបមួយឆ្នាំមុន) ហើយឥណទានសម្រាប់វិស័យឯកជនកើន ១០% (៣៤,១% ធៀបមួយឆ្នាំមុន) ដែលបង្ហាញពីកំណើនការផ្តល់ប្រាក់កម្ចីទៅឲ្យក្រុមហ៊ុនឯកជន។

## ស្ថានភាពក្រីក្រ

ការលក់ពលកម្ម និងការរកចំណូលពីរបរលក់ដូរតូចតាច ជាប្រភពចំណូលចម្បង សម្រាប់ពលករងាយរងគ្រោះទាំងប្រាំបួនក្រុម និងគ្រួសារពួកគេ។ នៅខែឧសភា ចំណូលប្រចាំថ្ងៃជាមធ្យមរបស់អ្នកស៊ីឈ្នួលធ្វើស្រែ និងអ្នករត់ម៉ូតូឌុប បានធ្លាក់ចុះ រីឯក្រុមផ្សេងទៀតរកចំណូលបានច្រើនជាងមុន។

អ្នកស៊ីឈ្នួលធ្វើស្រែរកចំណូលបាន ៦៤២៧រៀល/ថ្ងៃ ឬធ្លាក់ចុះ ០,១% ធៀបនឹងមួយឆ្នាំមុន ប៉ុន្តែកើន ១១% បើធៀបនឹងកាលពីខែកុម្ភៈ ដោយសារពលករក្រុមនេះថយចំនួន ដូច្នេះអាចទារកម្រៃបានខ្ពស់ជាងមុន។ ជាមធ្យម ពួកគេចំណាយអស់ ៤១១៨រៀល/ថ្ងៃ ក្នុងនេះ ៨៥% ជាចំណាយលើអាហារ។

ចំណូលប្រចាំថ្ងៃរបស់អ្នករត់ម៉ូតូឌុប ធ្លាក់ ១៣% ធៀបនឹងបីខែមុន (៨,០% ធៀបមួយឆ្នាំមុន) មក ១២.៥២២រៀល។ អ្នកឆ្លើយសម្ភាសន៍ ៥០% ស្នាក់នៅផ្ទះជួលក្នុងក្រុងភ្នំពេញ ដោយផ្ទះនីមួយៗមានមនុស្សស្នាក់នៅជាមធ្យមបីនាក់។ ក្នុងចំណាយប្រចាំថ្ងៃរបស់ពួកគេ ចំណាយឈ្នួលផ្ទះ មានត្រឹម ១,៣% រីឯចំណាយលើម្ហូបអាហារមាន ៩៥%។ ប្រាក់ចំណូលនេះ ពួកគាត់អាចចិញ្ចឹមគ្រួសារបាន លុះត្រាតែសមាជិក មានការងារធ្វើដែរ។

ចំណូលប្រចាំថ្ងៃរបស់អ្នករើសអេតចាយ កើនលឿនណាស់រហូតដល់១០.៤៤០រៀលឬកើន២៦%ធៀបនឹងឆ្នាំមុននិង១០%ធៀបនឹងបីខែមុន។ មានមនុស្សកាន់តែច្រើនបានចូលធ្វើការនេះ ប៉ុន្តែពួកអ្នកឆ្លើយសម្ភាសន៍ នៅតែរកចំណូលបានច្រើនជាងមុន ព្រោះស្គាល់កន្លែងរើសអេតចាយយ៉ាងច្បាស់។ ពួកគេត្រូវធ្វើដំណើរទៅកន្លែងរើសអេតចាយ ធ្វើឲ្យចំណាយដឹកជញ្ជូនឡើងខ្ពស់ដល់លំដាប់ទី២ បន្ទាប់ពីចំណាយលើម្ហូបអាហារ។

អ្នកលក់បន្លែតូចតាច រកចំណូលបានជាមធ្យម ១១.៥៧១ រៀល/ថ្ងៃ ឬកើន ១៦% ធៀបនឹងខែកុម្ភៈ។ អ្នកឆ្លើយសម្ភាសន៍ ៨៥% ជាអ្នកមកពីខេត្ត និងមាន ៤៧% ត្រូវធ្វើដំណើរទៅលក់ដូរ និងត្រឡប់មកផ្ទះវិញជារៀងរាល់ថ្ងៃ។ ក្នុងចំណាយប្រចាំថ្ងៃ ភាគច្រើនជាម្ហូបអាហារ និងការធ្វើដំណើរ។ អ្នកលក់បន្លែតូចតាចតែងស្វែងរកប្រាក់កម្ចី ឬឲ្យសមាជិកគ្រួសារខ្លះទៀតទៅធ្វើការ ប្រសិនបើចំណូលរបស់គាត់មិនអាចផ្គត់ផ្គង់គ្រួសារបាន។

ចំណូលប្រចាំថ្ងៃរបស់ កម្មករសំណង់មានជំនាញធ្លាក់ចុះ ៦,៧% ធៀបនឹងខែកុម្ភៈ មកត្រឹម ១៤.១៣៦រៀល រីឯចំណូលប្រចាំថ្ងៃរបស់កម្មករសំណង់គ្មានជំនាញកើន ៩,៤% ដល់ ១៣.៧២៥រៀល។ បន្ទាប់ពីម្ហូបអាហារ ចំណាយធំទី២ សម្រាប់កម្មករសំណង់មានជំនាញ គឺការដឹកជញ្ជូន រីឯសម្រាប់កម្មករសំណង់គ្មានជំនាញ គឺឈ្នួលផ្ទះ។ កម្មករសំណង់មានជំនាញ អាចសន្សំប្រាក់បានច្រើនជាង កម្មករសំណង់គ្មានជំនាញ។

ចំណូលប្រចាំថ្ងៃរបស់អ្នកបម្រើតាមភោជនីយដ្ឋានកើន ៣,៣% ធៀបនឹងបីខែមុន ដោយសារជាសំខាន់ កំណើនអតិថិជន។ មានអ្នកឆ្លើយសម្ភាសន៍តែ ១៥% ប៉ុណ្ណោះ ដែលអាចសន្សំប្រាក់សម្រាប់ថ្ងៃអនាគត។ ក្រុមនេះតែងទទួលបានកន្លែងស្នាក់នៅពីម្ចាស់ហាង ដែលជាការសន្សំសំចៃមួយយ៉ាងធំ។ អ្នកលីសែងរកបាន ១២.៨២៣រៀល/ថ្ងៃ ឬ កើន ០,៦% ធៀបនឹងបីខែមុន។ ពួកគេចំណាយជាមធ្យម ១០.០៧០រៀល/ថ្ងៃ និងជាសំខាន់ទៅលើម្ហូបអាហារ និងការដឹកជញ្ជូន។ ចំណូលរបស់អ្នកធាក់ស៊ីក្លូកើន ១១% ធៀបនឹងបីខែមុន។

ចំណូលប្រចាំថ្ងៃរបស់កម្មករកាត់ដេរធ្លាក់ចុះ ២,២% ធៀបនឹងខែកុម្ភៈ មកត្រឹម ៩៧៧៦៛។ អ្នកឆ្លើយសម្ភាសន៍ ៥៥% ធ្វើការផ្នែកដេរ។ ជាមធ្យម កម្មករកាត់ដេរធ្វើការ ៥៨ម៉ោង/សប្តាហ៍ ហើយរំពឹងចង់បានការងារក្រៅម៉ោងបន្ថែម ដើម្បីរកប្រាក់បានច្រើន។ ពួកគេអាចផ្ញើប្រាក់ខ្លះទៅឲ្យអ្នកផ្ទះ ប៉ុន្តែវាមិនទាន់គ្រប់គ្រាន់សម្រាប់ចិញ្ចឹមជីវិតឡើយ។ ទោះយ៉ាងនេះក្តី ពួកគេមិនចង់ប្តូរការងារទេ ព្រោះគ្មានជំនាញអ្វីផ្សេងក្រៅពីការកាត់ដេរនេះ៕

---

*តពីទំព័រ ១៤* **កំណែទម្រង់វិស័យជលផល...**

ជីវភាពរស់នៅ និងដល់សន្តិសុខស្បៀងរបស់ប្រជាជនរាប់លាននាក់។ ដោយសារបឹងទន្លេសាបមានសារៈសំខាន់ ចំពោះសេដ្ឋកិច្ចនៅជនបទ ការគ្រប់គ្រងបឹងទន្លេសាបប្រកបដោយចីរភាព គឺជាការសំខាន់ណាស់ដើម្បីកាត់បន្ថយភាពងាយរងគ្រោះរបស់គ្រួសារក្រីក្រ និងចូលរួមចំណែកពង្រឹងស្ថិរភាពសង្គម។ កំណែទម្រង់វិស័យជលផលបានផ្តល់នូវឱកាសជាច្រើន សម្រាប់ការពង្រីកអត្ថប្រយោជន៍ទាំងនេះ ប៉ុន្តែវាទាមទារឲ្យមានកិច្ចសហការគ្នាយូរអង្វែង រវាងអ្នកពាក់ព័ន្ធទាំងអស់ ដើម្បីស្វែងរកនូវគំនិតច្នៃប្រឌិតថ្មីៗសម្រាប់ការគ្រប់គ្រងផ្នែកស្ថាប័ន ដើម្បីវាយតម្លៃ និងរៀនសូត្រពីបទពិសោធន៍ទាំងនោះ និងដើម្បីយកវាមកធ្វើការកែសម្រួល និងធ្វើបច្ចុប្បន្នភាព ដោយយោងទៅលើបទពិសោធន៍ដែលរៀនសូត្របាន៕

**Suggested Reading**


Kurien, John, So Nam and Mao Sam Onn (2006), “Cambodia’s Aquarian Reforms: The Emerging Challenges for Policy and Research” (Phnom Penh: Inland Fisheries Research and Development Institute, Fisheries Administration)

Ratner, Blake (2011), “Common-Pool Resources, Livelihoods, and Resilience-Critical Challenges for Governance in Cambodia”, IFPRI Discussion Paper 01149 (Penang: WorldFish)

Ratner, Blake (2006), “Community Management by Decree? Lessons from Cambodia’s Fisheries Reform”, Society and Natural Resources, 19, pp.79-86

Ratner, Blake, Guy Halpern and Mam Kosal (2012), *Catalyzing Collective Action to Address Natural Resource Conflict: Lessons from Cambodia’s Tonle Sap Lake,* CAPRi Working Paper No.103 (Washington, D.C.: International Food Policy Research Institute) http://dx.doi.org/10.2499/CAPRiWP103

WorldFish (forthcoming), “After the Reforms: Strengthening Governance of Tonle Sap Aquatic Resources”(Phnom Penh: WorldFish)